អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកោលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី





ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៦

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

# អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្តីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្តីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្តុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្តុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **គិរម្សង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្តែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

# ច្បាប់កេរកាលថ្មី

## LES BON CONSEILS

នេះបទព្រហ្មប្រាជ្ញប្រាយ
ប្រដៅកូនចៅផង
កត្តិកខ្មែតគ្មេរគ្មាន់
ទឹកស្រែជន់លិចស្រូវ
កិរកាលពីព្រេងព្រឹទ្ធ
ខ្ញុំលើកកិរកាលថ្មី
ក្នុងថ្ងៃពេញបូរមី
ឆ្នាំចរចត្វាក្សត្រ
សាសនាព្រះសាមណៈ
ហុកសិបកំចាយ
កិរកាលដំណាលទុក
ដំណាតរៀងទៅ
កូនអើយពាក្យអាពុក
អនិស្រោយរាយបាលី
គួរស្តាយកេរ្តិ៍ម៉ែឪ
កិរិយាណាខុសច្បាប់
ម្តាយអាពុកនឹងកូន
ឃើញខុសកុំដេញដោល
ល្ងង់ខ្លៅត្រូវតែសួរ
យកពាក្យផ្អែមជាមុន
ទោះម៉ែឪស្លូតកាច
ម្តាយជេរពីរបីម៉ាត់
ប្រដៅត្រូវតែស្តាប់
ម្នោម្នះចចេសរឹង
ធមិអាចិចេះតែភ្លេច
ខ្ញុំអធិប្បាយលើកល្បត់ល្បង
ចងជាច្បាប់ខុសនិងត្រូវ ។
ក្នុងវស្សន្តរដូវ
នៅសំណល់សំណាបខ្ចី ។
ដើមគំនិតពីសេដ្ឋី
ថែងសេចក្តីជាបរមត្ថ ។
ម៉ោង៨ព្រលប់ស្ងាត់
ផាត់សករាជកន្លងឆ្ងាយ ។
បានពីរពាន់បួនរយប្លាយ
ចាត់អធិប្បាយពីខុសត្រូវ ។
ជាទំនុកដំណែលនៅ
តម្រូវចិត្តជនប្រុសស្រី ។
ជាទំនុកទំនើបថ្មី
អាពុកស្តីអោយកូនស្តាប់ ។
កិរិយាត្រូវអោយខំត្រាប់
គួរក្រឡាប់ក្រឡាស់ចោល ។
បីដូចខ្លួននិងស្រមោល
កុំថ្កោលទោសអ្នកមានគុណ ។
ពាក្យអោយគួរកុំអោយស៊ុន
ទន់លំទោនឱនប្រតិបត្តិ ។
គួរតែខ្លាចដូចមហាក្សត្រ
គួរតែស្ងាត់ស្ងៀមអោយឈឹង ។
យកតម្រាប់កុំទទឹង
នឹងហើយហៅកូនសេសកម្ម ។
ជេរប្រទេចចេះតែចាំ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

អាពុកពត់ទៅស្តាំ អកុសលកម្មទាញទៅឆ្វេង ។
អវជាតបុត្រ ខូចបំផុតតាំងពីក្មេង
ប្រព្រឹត្តព្រើលផ្សេងៗ បើលេងអ្វីស្តីមិនស្តាប់ ។
មិនស្តាយជាតិកំណើត ល្ងង់ស្លុតស្លើតដល់ចាស់ស្លាប់ ។
ត្រឹមត្រូវមិនសូវស្តាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។
ម៉ែឪមានគុណណាស់ មិនសំពះខ្មាសអៀនដៃ
បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន ។
ឆ្លើយបាទចាះចាំខ្ញុំ វាបរម្យទមនឹងសន្តាន
ម៉ែឪឯងក្នុងឋាន ហ៊ានឆ្លើយអឺអញអឺអើ ។
អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ ដើរតាមលំអានឪ ។
ប្រដៅទទួលយក ចេះលៃលកស្តាប់ខុសត្រូវ
ស្រណុកញាក់ធ្លាក់ផ្លូវ មិនសូវភ្លេចដំបូន្មាន ។
អតិជាតបុត្រ ល្អបរិសុទ្ធស្គាល់សីលទាន
នាំឪទៅនិព្វាន ឈានទៅរកកន្លែងសុខ ។
ចេះលើសគេដរាប ជឿបុណ្យបាបប្រេតនរក
មិនល្មោភនឹងមូត្រលាមក ភ័យនឹងភក់ភពសង្សារ ។
នេះគឺដើមបាលី បុត្រទាំងបីបែបកិរិយា
ស្រឡាញ់ណាស្អប់ណា តាមសញ្ញាចូលចិត្តចុះ ។
អវធ្លាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស
អតិជាតិមារយាទខ្ពស់ អនុនោះយ៉ាងកណ្តាល ។
អតិ១០០មានមួយ គួរតែស្ងួយដាក់លើក្បាល
អវគឺស្រើបស្រាល ត្រអាលយកតែពីរយ៉ាង ។
អតិជាតិកំណើត គំនិតកើតពីកសាង
កុសលតម្កល់ខាង សំណាងកើតពីគំនិត ។
អនុអានាងអើយ ខ្លួនធំហើយអោយចេះគិត
ចេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ ។
រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឪ
ធុនថោកជ្រកខុសត្រូវ អ្នកកុំទៅខ្លាចបន្ទា ។

ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា
ឈានឈរពិចារណា ឆ្ការអោយស្អាតសឹងដើរតាម ។
កុំដើរភ្លើភ្លេចខ្លួន ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ
ជ្រកម្លប់សំណាក់នៅ កុំបោះពៅផ្ចប់គល់ឈើ ។
ឆេះខ្ទោចសំបកក្រោម ស្រពោនញោមស្លោកស្លឹកឈើ
មានភ្នែកអោយចេះមើល កុំល្ងីល្ងើល្ងង់ល្ងិតពេក ។
រៀនដើរអោយមើលផ្លូវ ធ្វើស្រែស្រូវអោយមើលមេឃ
ម្លប់ធ្លកធ្លាប់ជ្រកដេក ជាដំណេកអ្នកដំណើរ ។
ដំណែលដែលគេដាក់ ជាដំណាក់ទំនួលផ្ញើ
ចំណាំចាំគ្រាន់បើ ដើរក្រោយៗគ្រាន់ជ្រកទៀត ។
ឈើណាទោសសត្រូវ ដុះជិតផ្លូវនាំចង្អៀត
ជិតពប់យប់អាធ្រាត្រ ឆ្លៀតកាប់ចេញកុំទុកវា ។
បន្ទាគល់ដង្គត់ កន្លែងផុតតែភ្នែកជា
ដើរយប់ជិតពប់ពារ ក្រែងគ្រោះគ្នាអ្នកដើរក្រោយ ។
គ្នាមុតកុំចាំផ្ទាន់ ឃើញគួរជាន់កុំបណ្ដោយ
បណ្ដើរមើលខ្លាំងខ្សោយ អោយពិនិត្យពិចារណា ។
ពាក្យពិតត្រង់ប្រាកដ ត្រូវច្រើនបទច្រើនប្រការ
ប្រកបជាប្រស្នា ប្រាជ្ញាអាប់ស្លាប់នឹងឆ្ងល់ ។
ផ្លូវពិតទាំងជិតទាំងឆ្ងាយ សព្វសុសសាយមិនសេសសល់
អ្នកណាប្រាជ្ញាដល់ ដឹងយោបល់ច្រើនកន្លែង ។
កូនអើយការកើ្តឈ្មោះ កុំចង់រស់តែម្នាក់ឯង
គិតអ្វីគិតអោយវែង ក្រែងក្រក្រោយស័យគំនិត ។
កំណើតរាល់រូបកាយ ចេញជូញឆ្ងាយស្ដាយជូញជិត
ចិញ្ចឹមជន្មជីវិត គិតអោយស្រេចទើបបានស្រួល ។
ធ្វើស្រែចង់បានស្រូវ ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល លើកទំនប់អោយមាំមួន ។
កូនអើយកើ្តមេបា ចាំរក្សាមើលថែថួន
ធុញថប់ថយថោកខ្លួន ជួនជាក្សត់គេថាខ្សោយ ។
ស្រូវក្រោយអង្គរថ្លៃ លក់សំចៃទុកឆ្នាំក្រោយ

អ្នកក្ររកញយ១ អោយអ្នកសុំជាងអ្នកខ្ចី ។
សប្បុរសពេកថយធន មួទូជនថយរាសី
ប្រពន្ធល្អច្រើនអាប់ប្តី ពាក្យអប្រិយចាញ់អាត្មា ។
ឈើផ្លែចាញ់សន្លឹក ត្រីរំរឹកទឹកមិនថ្លា
កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស ។
នឹងអោយ១មើលភាព អោយអ្នកទាបជាងអ្នកខ្ពស់
អ្នកទិញឈប់សិនចុះ ក្នុងតែរស់មិនស្លាប់ងាយ ។
កំណាញ់ហួសកំណត់ ពាក្យអ្នកខ្សត់ខ្សបនិយាយ
ទេវតាផ្តន្ទាទាយ រលាយអស់រលស់ឯង ។
សទ្ធាមើលធនធាន ជាតិអ្នកមានមិនអង្វែង
កំណាញ់ដោយកន្លែង គ្រែងគ្រោះក្រដល់ឆ្នាំក្រោយ ។
អ្នកក្រខ្ចីនេះកុំ អ្នកមានសុំនោះគួរអោយ
អ្នកប្រាជ្ញអង្គាសញយ អស់ក៏ដោយអោយទៅចុះ ។
អ្នកក្របានជាហាម ពិបាកតាមទៅឯណោះ
ទាល់ទឹកចូលច្រមុះ ច្រើនកើតឈ្លោះពីព្រោះយល់ ។
អ្នកមានគេមានខ្មាស សងរហ័សមិនអំពល់
ជូនយើងមានរវល់ គេស្គាល់មុខស្រណុកខ្ចី ។
អ្នកក្រ១ទាំងចិត្ត ស្រូវវស្សារល្អិតអោយមើលល្អី
វាលល្អកន្លាំងបី ទាន់ស្រូវថ្មីទារឆាប់បាន ។
ជូនក្រែងឯងក្រវិញ ទោះដូរទិញមើលប្រមាណ
ជឿបុលខ្ចីសន្មាន កុំហ៊ានពារកញ្ជើធំ ។
ខ្លួនក្រកុំចង់ធាត់ កុំងាយមាត់អាងតែសុំ
ជឿខ្ចីល្អីក្រមុំ ស្រូវឯងទុំស្រណុកសង ។
បើជឿខ្ចីគេអោយ កុំទៅញយគេអោយខ្មង
ឯណេះឯណោះផង កុំច្រើនដងគេមើលងាយ ។
ក្រលុយកុំងុយដេក ចូលដំណេកកុំនិយាយ
សំពត់ញាត់សំពាយ រាយរើសរៀបញាត់សំពៀត ។
រៀបដេកសំពះគុណ កុំដេកស៊ុនអោយប្រុងស្មៀត
ភ្លើងឈេះយប់អធ្រាត្រ កណ្តៀតទូលប្រមូលរត់ ។

ខ្លួនរាស្ត្រក្រមាសប្រាក់ ភើចកន្ទ្រាក់អាវសំពត់
ទំរាំភ្លើងរលត់ ស្លៀកផ្គង់ផ្គត់សោះខ្មាសគេ ។
កូនអើយគិតអោយគ្រប់ រៀងរាល់យប់កុំទំនេរ
ជាងដេកលក់ទទេ យល់សព្វដេរបកសាចក្រៅ ។
ទំលាប់មាត់មមើ ស្រែកថាយើៗ អៅៗ
ចោរខ្លាំងខ្មោចចិត្តខ្មៅ ហៅមេខ្មៅរៃអោយខ្ពុក ។
ដេកផ្ទៀងជាងអង្គុយ ល្ងាល្ងាន់ល្ងុយកុំទ្រាំងក់
ពីល្ងាចដេកកុំលក់ មាន់រងាវដក់ស៊ីម្លូស្លា ។
ជាងល្វីតឥតអំពើ ឥតអ្វីធ្វើសូត្រធម៌អាថិ
បើច្បាស់វិបស្សនា ស្មាស្មាធិ៍ស៊ីងប្រឹងអោយស្មោះ ។
គង់ខ្មើយដេកកើយស្មុគ្រ គ្រប់អោយសុខសូត្រអម្បោះ
កុំដាក់ដោយកៀនកោះ អស់នឹងសត្វកណ្ដៀរកោរ ។
កណ្ដុរកន្លាតកាត់ ដល់កំណាត់ខានដេរខោ
ជូនកាលមានអាចោរ លបលបលួចលីទៅបាត់ ។
កុំដាក់ឆ្ងាយប្រយោល ទុកជាចោលមិនប្រយ័ត្ន
ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្កោលគោ ។
បង្ការក្រែងមូសខាំ ត្រូវចំណាំខ្យល់ជំនោរ
បាយកកផ្អកម្ហូបដោរ អោយអាលោស៊ីចាំសេះ ។
កំណើតផ្ដៃញីឈ្មោល ដេកចំនួលតែនឹងផេះ
រៀនប្រើមើលចំណេះ រិះចំណាំតាមកិរិយា ។
ទោះប្រើកូនតូចធំ ឬប្រើខ្ញុំអោយធ្វើការ
ធ្វើកលយល់ប្រាជ្ញា អាណាហ៊ានប្រើទៅឆ្ងាយ ។
អាខ្លាចប្រើតែជិត ឥតគំនិតប្រើរៀងអាយ
ខុសម្ដងកុំជេរម្ដាយ ពេលដល់បាយកុំនាំឈ្លោះ ។
មនុស្សឃ្លានវាហ៊ានឆ្លើយ ស៊ីរួចហើយបន្ទោសចុះ
បានឆ្អែតប៉េងពេញពោះ ស្ដីខុសត្រូវមិនសូវខឹង ។
កូនអើយពាក្យអាពុក ចំណាំទុកពីត្រឹមណឹង
ធ្វើប្រុសអោយខំប្រឹង រៀនអោយដឹងស្គាល់ពុតស្រី ។
មារយាទនិងមាយា ម៉្យាងចិត្តជាចេះថ្នមប្ដី

ប្អូនស្លាប់រស់វាហើ យកពីរបីនេះមិនបាន ។
កុំលោភច្រើនៗ ព្រួយ យកតែមួយសុខក្សេមក្សាន្ត
ចិត្តស្រីទាំងប៉ុន្មាន ហ៊ានប្រមូលម៉ៅមិនខុស ។
មិនខូចគ្រប់តែស្រី ល្អពីរបីជឿចាំចុះ
ជាតិស្រីលោភលើប្រុស នោះមិនខុសពីស្រីណាមួយ ។
ខ្លាំងខ្សោយកុំអោយខ្សត់ ទោះនឿយហត់កុំលំអួយ
ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំត្អូញត្អែរ ។
ខ្លួនខ្លាំងកុំគិតខ្លាច ស្រីៗ កាចស្លូតដោយខែ
រដូវធ្វើស្រូវស្រែ ចែប៉ប្រែស្តីលើប្រុស ។
ខែស្ទូងនិងខែច្រូត កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់ រលីងអស់អំពីដី ។
ជញ្ជូនដាក់ជង្រុក ពូជពេញទុកស្បោងពីរបី
ដំណើបបួនដប់ល្អី ស្រីៗ ស្លូតហើយខែនឹង ។
ស្លូតផុតនៅខែមាឃ ស្តីធ្ងន់ពាក្យមិនសូវធ្ងន់
បើប្រុសៗ មិនដឹង ប្រឹងតែព្រួតស្អប់ស្រីៗ ។
ម៉្យាងទៀតមារយាទខូច មាយាបេះក្រូចមាយាដកខ្ទឹ
មានប្រុសសាហាយថ្មី រឹតថ្នមប្តីមិនអោយអាក់ ។
អីអើតែមាត់ក្រៅ ចិត្តមួម៉ៅគ្មានត្រជាក់
ត្រីសាច់ល្អលួចលាក់ ដាក់តែឆ្អឹងអោយឯងស៊ី ។
បញ្ឆោរចេះបញ្ឆើ បញ្ឆោតប្រើឯងរកវី
វរវឹកព្រួតប្រុសពីរ ស៊ីទាល់ងាប់គាប់សងខាង ។
មួយទៀតផិតកំឡោះ ស្រឡាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្តីលាសំណាង ទាស់ក្មេងក្មាងទារសំបុត្រ ។
បើប្តីមិនព្រមលែង លបជំទែងជំទយរត់
មួយទៀតខូចបំផុត មត់អោយប្រុសសម្លាប់ប្តី ។
ម៉្យាងទៀតមារយាទជា មានច្រើនគ្នាក្នុងលោកិយ
ប្រាកដពេញជាស្រី ប្រុសពីបីស្មាលាកម្ម ។
ស្លាប់រស់មួយនឹងមួយ មិនចង់ព្រួយយកប្រុសប្រាំ
ប្តីស្លាប់បួនដប់ឆ្នាំ ចាំសីលទានមិនមានទៀត ។

ធ្វើបុណ្យផ្សងសច្ចា សុំប្រាថ្នាជួបរាល់ជាតិ
អុចធូបដេកអោបធាតុ កណ្ដៀតថៅកោរកាន់ទុក្ខ ។
និយាយពីពុតប្រុស ចូរចាំចុះជាទំនុក
ដំណេតទៅមុខ អាពុកប្រាប់អោយស្រីចាំ ។
ប្រពន្ធមួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្កាំ
កាចស្លូតរហូតឆ្នាំ ចាំដរាបដល់រូបា ។
កាចម៉្យាងខាងល្ងាចព្រឹក រឿងបាយទឹកថ្នាំម្លូស្លា
កាចម៉្យាងរឿងធ្វើការ ម៉្យាងទៀតណារឿងប្រចណ្ឌ ។
ប្រជុំជាតិចិត្តប្រុស ត្រូវនឹងខុសជាកំណាន់
គំនិតល្អសំខាន់ ប្រកាន់មើលឥរិយាបថ ។
ប្រចណ្ឌរាវរាល់ឈ្មោះ ច្រើនកើតឈ្លោះទៅជាខ្សត់
មួយឃើញជាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
លកលៃតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន
ខូចម្ដងខាតប៉ុន្មាន រាប់អានអោបក្រសោបទៀត ។
មួយលកលៃទាំងពីរ នៅរកស៊ីដោយសារញាតិ
ស្រីមាយាឥតមារយាទ ស្មាលាជាតិមិនអោយជូន ។
ប្រចណ្ឌទាំងបីបទ គួគួចកត់ទុកក្នុងខ្លួន
លក់ពីពេញចំនួន គួនគំទុកយកជាច្បាប់ ។
ប្រចណ្ឌហើយយកទៀត ហៅជូជាតិមារយាទអាប់
កូនណាយកតម្រាប់ ស្លាប់នឹងស្រីៗមើលងាយ ។
ទោសតិចកុំទាញផ្សំ ឃើញមិនចំកុំនិយាយ
កុំចាប់ស្ដើររវើរវាយ នាំអោយវល់អំពល់ចិត្ត ។
ពុតប្រុសនិងពុតស្រី ចប់សេចក្ដីពីក្បត់ផិត
រៀងរើសណាសុខចិត្ត គិតសំគាល់រាល់រូបកាយ ។
បើមានកូនក្រមុំ គួរតែកុំបណ្ដោយឆ្ងាយ
អោយមើលនាយមើលអាយ ស្រេចនៅម្ដាយរក្សាកូន ។
ប្រយ័ត្នកុំអោយឃ្លាត ភ្លាត់មារយាទមិនសុទ្ធសូន្យ
កុំទុកចិត្តបងប្អូន ជីដូនមួយជួយរក្សា ។
ក្រមុំមានម្រាក់មិត្ត មេមួយគិតនាំកិច្ចការ

កុំជឿចិត្តនរណា　　មើលកិរិយានៃកូនឯង ។
ទោះស្ទូងដកយប់ថ្ងៃ　　ដើរយកដៃដាច់សង្វែង
ប្រុសខូចលួចបន្លែង　　តែទាស់ភ្នែកបែកមេបា ។
ច្រើនណាស់តែសែនខ្មោច　　កើ្តអសោចផុតអាសា
នាំកូនឡើងសាលា　　គេថាអោយជំងឺចិត្ត ។
បើមានកូនប្រសា　　មិនទាន់ការគួរអោយប្រិត
កុំអោយបំរើឆ្អិត　　អាណិតវា១សងគុណ ។
យប់ថ្ងៃចូលប្រតិបត្តិ　　គាតក្រវាត់រត់រែកពុន
អាចនឹងច្រើនជឿមុន　　ស៊ុនអំពីឪពុកម្តាយ ។
រក្សាកូនប្រពន្ធ　　រកទ្រព្យធនចង់ធូរចាយ
ជួញជិតគំនិតឆ្ងាយ　　ជួញរៀងអាយរក្សាគុណ ។
អំពើបាបកុំរៀន　　កុំអៀនប្រៀនក្នុងការបុណ្យ
លាងទោសចេញជាមុន　　ទើបធ្វើបុណ្យចំរើនផល ។
បើនឹងចង់គង់ទ្រព្យ　　កុំទម្លាប់សាងអកុសល
របិញរបុញវៀចកាច់កល់　　ទេវតាផ្តល់ផ្តាច់ធនធាន ។
កុំឈ្នានីសអ្នកក្សត្រ　　កុំបំភ្លាត់ទ្រព្យអ្នកមាន
បើខ្លួនខ្សត់អត់ឃ្លាន　　រៀនតែរកតាមទៀងត្រង់ ។
ជួញខាតកុំឈប់ខាន　　បើចង់បានកុំឃ្លាចបង់
ខ្លាចបាត់អោយផ្ចិតផ្ចង់　　ប្រុងថៃទាំអោយមាំមួន ។
កុំភ្លើធ្វើជាភ្លេច　　ភ្លាត់បន្តិចខ្លាចក្រែងជួន
ក្រែងចោរចូលមកពួន　　លួនលបលួចយកទ្រព្យទៅ ។
ប្រហែសតែងតែបាត់　　ប្រុងប្រយ័ត្នតែងតែនៅ
គិតសព្វគ្រប់ដោយផ្លូវ　　សូវទ្រាំនឿយកុំទ្រាំក្រ ។
នៅផ្ទះស្រះរបង　　របាចងអោយជាប់ល្អ
ប្រើប្រាស់ខ្ញុំកំដរ　　អោយបរិភោគដោយខ្លួនឯង ។
នឹងប្រើទៅហៅមក　　កុំគំហកយកកំហែង
កុំហាឡើងហងឯង　　ក្រែងកំហល់ទល់កំហឹង ។
កុំហួសពាក្យសម្តី　　ការអ្វី១អោយចេះថ្លឹង
កុំប្រើព្រួតលើប្រឹង　　ក្រែងកើតខឹងវានាំខាត ។

មនុស្សខឹងច្រើនៗខុស　មនុស្សច្រើនឈ្លោះច្រើនប្រមាថ
ការល្អមិនត្រូវខ្មាត　យើងចង់ស្អាតមិនខ្លាចយូរ ។
ចង់ប្រាជ្ញអោយខំប្រឹង　ចងក្បិនតឹងរកស៊ីធូរ
តំនិតមុនតំនូរ　រៀនមានគ្រូមានគេរាប់ ។
បំរើឪពុកម្តាយ　អ្នកនៅឆ្ងាយគេច្រើនគាប់
អ្នកណាបំរើខ្ជាប់　ធ្លាប់តែខុសមិនដែលត្រូវ ។
ជាតិមនុស្សទោះខ្ពស់ទាប　មិនចោលភាពពីម៉ែឪ
ពាក្យមនុស្សវែងជាងផ្លូវ　ស្រូវច្រើនខួបខូចអង្ករ ។
របស់ទ្រព្យថោកថ្លៃ　ទុកសំចៃលៃអោយល្អ
អុងអាងពាងក្រឡ　ត្រដរទិញកុំអោយខ្វះ ។
កើតមកខ្លួនជារាស្ត្រ　ក្រប្រាក់មាសអោយមានខ្មាស
សារពើគ្រឿងប្រើប្រាស់　អោយមានចាស់អោយមានថ្មី ។
ពូថៅដឹងកាំបិត　ពន្លាកខិតចបវែងខ្លី
ខ្សែសេះគោក្របី　ឫស្សីផ្តៅកាច់សង្រែក ។
ការងារកុំអោយក្រ　អាកក្រក់ល្អមានដោយឡែក
ថ្ងៃនេះរបេះបាក់បែក　ស្អែកខំរើធ្វើជាឆាប់ ។
ឈ្មោះការប្រើលើដី　កុំចាំស្រីតឿនប្រើប្រាប់
អោយមានគ្រប់ប្រដាប់　សំរាប់វាល់អោយសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក　អោយចេះដេកអោយចេះដើរ
ចេះសព្វគាប់ប្រសើរ　កុំចង់ហើរហួសភាពខ្លួន ។
ចង់ក្តីអោយរៀនច្បាប់　រស់នឹងស្លាប់អោយចេះក្បួន
ចេះអ្វីចេះអោយមួន　កុំបន្លំផ្លុំនឹងគេ ។
កុំដេកចាំសំណាង　កុំក្មេងក្មាងចាំបុព្វេ
ខំរកកុំទំនេរ　វរៀនរិះចេះអោយគ្រប់ ។
នឹងដើរស្វែងរកផល　មិនទាន់ដល់កុំអាលឈប់
ឈានខ្លាំងពេកជំពប់　បើដេកយប់អោយស្គាល់យាម ។
កុំដេកយូរទ្រមឹក　លកហួសព្រឹកខុសទំនៀម
តែភ្លឺឡើងភ្ញាក់ភ្លាម　ព្រហាមឡើងក្រោកធ្វើការ ។
ជាតិមនុស្សទោះប្រុសស្រី　រាស្ត្រមន្ត្រីជាធម្មតា

ពេលព្រឹកតែងឧស្សាហ៍ ថ្ងៃក្តៅល្ហែខិលល្អិតឆ្អឹង ។
ចង់ធំខំពីតូច បើខ្លាចខូចកុំឆាប់ខឹង
ការអ្វីអោយចេះថ្លឹង កុំប្រឹងជុះតាមដីរ ។
កុំចង់ខ្ពស់ស្មើមេឃ កុំខ្ជិនពេកអាប់រាសី
ទោះដើរនិយាយស្តី លៃអោយល្មមតែគួរសម ។
យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំអាលខំ
មិនជាក់មើលអោយចំ ក្រែងច្រឡំសជាខ្មៅ ។
ទម្លាប់ធំជាងច្បាប់ បើរៀនគ្រាប់កុំគ្រាប់ខ្លៅ
គ្រាប់ប្រាជ្ញអាចប្រដៅ អោយគេរៀនកុំអោយអស់
ស្រឡាញ់កុំញ៉េះញ៉ោះ បើខឹងទាស់កុំអោយទាយ ។
ផ្តែព្រុះកុំអោយព្រួយ ឃើញផ្តែដេកកុំមើលងាយ
កំណប់ដប់សំពាយ កុំនិយាយប្រាប់សំឡាញ់ ។
សំឡឹងមើលអោយសព្វ បើនឹងស្អប់កុំអាលបាញ់
ក្តីឈ្នះគេចុះចាញ់ កុំក្តាច់តាមផ្គន្ធាទៀត ។
បើខឹងកុំរំលោភ បើនឹងល្មោភអោយល្មមមាឌ
កុំរមាត់ក្រែងភ្លាត់ស្នៀត វាតហួសវង់ផុតគំនិត ។
កំណើតអាក្រក់ល្អ មាននឹងក្រពីគំនិត
ពីកាលបុព្វេពិត ងងឹតពេកមើលមិនយល់ ។
ដាំដូងអោយខំថែ ចង់ស៊ីផ្លែអោយដុតគល់
បើជូនសំណាងដល់ រវល់តែស៊ីឆ្ងាញ់ពិសា ។
ប្រាជ្ញប្រិតប្រៀនប្រដៅ ចូរកូនចៅពិចារណា
រំពឹងក្នុងប្រាជ្ញា ស្រាយបញ្ហានេះអោយដឹង ។
នេះច្បាប់កេរកាលថ្មី អស់សេចក្តីតែប៉ុណ្ណឹង
កូនប្រុសអ្នកខំប្រឹង សំឡឹងចាំតទៅមុខ ។
ពីឆ្នាំ ច តទៅ ខំធ្វើស្រូវដាក់ជង្រុក
អាសូរពាក្យអាពុក ទុកអោយកូនចៅគ្រប់គ្នា ។
អាពុកកាន់តែចាស់ ស្ពាយខ្លួនណាល់ចូលជរា
ពាក្យពិតប្រាំរយឆ្លា ជាសូរេចម្លេះឯងហោង ។
អ្នកប្រាជ្ញភិរម្យល្បី លើកច្បាប់ថ្មីអស់ល្បត់ល្បង

ឈ្មោះ អ៊ី ហៅ **ខ៊ុយ** ផង
ខ្ញុំសូមផ្សងសច្ចា
មូលកូនមូលប្រពន្ធ
ស្លាលាក្រលំបាក
សូមល្អពង្សរូបកាយ
ប្រាជ្ញាកុំទើសទាល់
សូមជាប់សីលបរិសុទ្ធ
អានិសង្សបុណ្យខ្ញុំបាន
សម្បត្តិសួគ៌ាល័យ
ពីជាតិនេះទៅមុខ
បងប្អូនកុំខ្វាត់ខ្វាយ

ចងជាច្បាប់សំរាប់ជន
កើតជាតិណាសូមមានបុណ្យ
ធនសម្បត្តិសម្បូរចាយ
សូមជៀសចាកចតុរាបាយ
កុំអោយឆ្ងាយពីព្រះពុទ្ធ
ចេះអាថ៌ធម៌អោយមាំមុត
រលត់ទុកសោករោគភ័យ
សាងប៉ុន្មានក្នុងលោកិយ
កុំបីឃ្លាតវវាតវែងឆ្ងាយ ។
មូលអាពុកជួបមូលម្តាយ
អធិប្បាយថែងចប់ងវិ

អ្នកព្រះភិរម្យភាសា អ៊ី ហៅ **ខ៊ុយ**